# ប្រកាស មាឃបូជា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្សការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ

តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។

*ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។*

និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន

ភគវតា តំ ធម្មំ អាទរេន នមស្សាម ។

*ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខទាំងពួង ព្រះធម៌នោះជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះធម៌នោះដោយគោរព ។*

សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ

តំ សង្ឃំ អាទរេន នមស្សាម ។

*ព្រះអរិយសង្ឃណា លោកប្រតិបត្តិដើម្បីកំចាត់បង់នូវ សេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវក័នៃ ព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។*

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៊ាន់ អ៊ុំឌ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១២

